# កិច្ចព្រមព្រៀង
## រវាង
## ក្រុមហ៊ុនស៊ីអិនឌីហ្គ្រី អិនធើណេសិនណាល (ខេអេច) ឯ.ក ជាមួយតំណាងកម្មករ
## និង
## តំណាងកម្មករ និយោជិត

នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ៨ និង ៣០នាទី ព្រឹក នៅក្នុងក្រុមហ៊ុន ស៊ីអិនឌីហ្គ្រី អិនធើណេសិនណាល (ខេអេច) ឯ.ក មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិត ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់ កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ន នៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងគ្មានការបញ្ជាទិញ ដែលជាហេតុមិនអាចអោយសង្វាក់ផលិតកម្ម ដំណើរការបាន។ ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ៦៩៥ នាក់ (ស្រី ៥៥០ នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ១៨២០នាក់ (ស្រី ១៤០៨នាក់) រយៈពេលព្យួរចំនួន ៣៨ ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០៧ ខែមិនា ឆ្នាំ២០២៣ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣។ ហើយនៅក្នុងអំឡុងពេលព្យួរការងារនេះ កម្មករ និយោជិត បានឯកភាពទទួលការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួល ៣០ ដូល្លា អាមេរិច ក្នុងខែនីមួយៗ ក្នុងអំឡុងពេលពេលព្យួរ សម្រាប់កម្មករ និយោជិតម្នាក់ៗ ដោយក្រុមហ៊ុនយល់ព្រមបើកប្រាក់ឈ្នួលមុខពេលព្យួរការងារជូនកម្មករ និយោជិត។

អង្គប្រជុំបានចប់នៅវេលាម៉ោង ៩: ០០ នាទី ព្រឹក នាថ្ងៃខែឆ្នាំដដែល ដោយភាគីទាំងសង់ខាងមានភាពស្និតស្នាល និងយោគយល់ និងសហការគ្នាយ៉ាងរលូន។

ថ្ងៃច័ន្ទ ០៨កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
កំពង់ស្ពឺ, ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣

**នាយកក្រុមហ៊ុន**

ក្រុមហ៊ុន ស៊ីអិនឌីហ្គ្រី អិនធើណេសិនណាល (ខេអេច) ឯ.ក
CNDEGRE INTERNATIONAL (KH) CO., LTD.
KINGDOM OF CAMBODIA

**ស្នាមមេដៃតំណាងកម្មករនិយោជិត**

អឿន កុសល    ឈុំ វីណា    ហ៊ិន ស្រីពៅ    វណ្ណ សៀលីន    ផូ គ្រឿន    ហេង ស្រីធំ

ផល មិនា    ម៉ន ថារុធ    សូ សុខឡី    ចែម និមល    ចៃ ឡុង    ឡុង ប៊ិន

អោម លក្ខិណា    សាត សេងលីម